# កិច្ចការបញ្ចប់មេរៀនទី៣៤- ការលក់ដូរ

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ព្រឹកនេះសុភីទំនេរ នាងបានឆ្លៀតពេលទៅជួយម្តាយលក់ដូរនៅឯផ្សារ ។

សុភី មិងម្តាយក្រោកពីនិទ្រាតាំងពីព្រលឹមអរុ រៀបចំបន្លែ ត្រី សាច់ និងគ្រឿងទេសដាក់រទេះ ដើម្បីយកទៅលក់ ។ ពេលមកដល់ផ្សារ សុភីស្ទុះស្ទា ជួយរើអីវ៉ាន់ពីរទេះ ដាក់លក់លើតូប។ នៅក្នុងផ្សារ មានមនុស្សច្រើនកុះករ ស្លៀកពាក់ស្អាតបាតខ្លះ ដើរទិញម្ហូបអាហារប្រចាំថ្ងៃ ខ្លះដើរទិញអីវ៉ាន់ប្រើប្រាស់ផ្សេងៗ ។ សុភីមានទឹកមុខញញឹមញញែមអញ្ជើញភ្ញៀវចូលទិញ ព្រមទាំងយកជំនាញគិតលេខដែលបានរៀនមកអនុវត្ត ។ តាំងពីព្រលឹមដល់ល្ងាច សុភី និងម្តាយមមាញឹកនឹងការលក់ដូរ ដោយមានភ្ញៀវចូលទិញជាហូរហែ ។ អ្នកភូមិ ប្រុស ស្រីចូលចិត្តទិញអីវ៉ាន់មីងសឿនណាស់ ព្រោះគាត់លក់តម្លៃថោកសមល្មម ។

ការប្រកបរបរលក់ដូរ ធ្វើឱ្យគ្រួសារមីងសឿន មានជីវភាពសមរម្យ ។

១. តើអត្ថបទខាងលើមានចំណងជើងដូចម្តេច ?

☐ក. មុខរបរកសិកម្ម ☐ខ. ការហាត់ប្រាណ

☐គ. មុខរបរចិញ្ចឹមត្រី ☐ឃ. ការលក់ដូរ

២. តើម្តាយសុភីប្រកបរបរអ្វី ?

☐ក. គ្រូបង្រៀន ☐ខ. គ្រូពេទ្យ

☐គ. លក់ដូរនៅផ្សារ ☐ឃ. កសិករ

៣. ពេលទំនេរ តើសុភីតែងតែឆ្លៀតពេលធ្វើអ្វី?

☐ក. ដាំបន្លែ ☐ខ. ជួយលក់ដូរម្តាយនៅផ្សារ

☐គ. ដើរលេងជាមួយមិត្តភក្តិ ☐ឃ. មើលទូរទស្សន៍

៤. ហេតុអ្វីបានជាគេចូលចិត្តទិញអីវ៉ាន់មីងសឿន?

☐ក. មានទំនិញច្រើនមុខ ☐ខ. មានទីតាំងនីមុខគេ

☐គ. តម្លៃថោកសមរម្យ ☐ឃ. មានទីតាំងធំទូលាយ

LIVEWORKSHEETS

៥. ហេតុអ្វីបានជាគ្រួសារមីងសឿនមានជីវភាពធូរធារ ?

☐ ក. ដោយសាររបរនេសាទ ☐ ខ. ដោយសារប្រកបរបរលក់ដូរ

☐ គ. ដោយសាររបរកសិកម្ម ☐ ឃ. ដោយសារឪពុកម្ដាយឱ្យលុយ

➢ សំណេរ

១. ចូរពន្យល់ពាក្យ "គ្រឿងទេស ភ្ញៀវ និទ្រា " ។

➢ គ្រឿងទេស ( ) ....................................................................................................

➢ ភ្ញៀវ ( ) ............................................................................................................

៣. ចូររៀនពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ឱ្យបានជាល្បះត្រឹមត្រូវ ។

ក.

| | | | | |
|---|---|---|---|---|
| ជា | រៀនសូត្រ ។ | សំណាង | ព្យាយាម | សិស្ស |

.............................................................................................................

ខ.

| | | | | | |
|---|---|---|---|---|---|
| សន្សំសំចៃ | របស់ប្រើប្រាស់ | យើង | ប្រាក់កាស | ត្រូវចេះ | និង |

.............................................................................................................

២. ចូររកសទិសសព្ទនឹងពាក្យ " ផ្សារ " ។

➢ ផ្សារ ( ន ) ......................................................................................................

➢ ផ្សារ ( កិ ) ......................................................................................................

➢ ផ្សា ( គុ ) .......................................................................................................

LIVEWORKSHEETS